01631624

F39/16

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# អង្គជំនុំជម្រះតុលាការកំពូល
# Supreme Court Chamber

**ផ្ញើពី/From:** ប្រធានអង្គជំនុំជម្រះតុលាការកំពូល
**President of the Supreme Court Chamber**

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩
Date: 26 November 2019

**ផ្ញើជូន/To:** អង្គភាពពេទ្យ
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
ភាគីទាំងអស់នៃសំណុំរឿង ០០២
**Medical Unit, Witness and Expert Support Unit WESU, All Parties of Case 002**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Nov-2019, 13:20
CMS/CFO: Sann Rada

**ចម្លងជូន/ CC:** ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល និងមន្ត្រីច្បាប់
**Judges of the Supreme Court Chamber; Legal Officer and Legal Consultants**

**កម្មវត្ថុ/ Subject:** ដីកាបង្គាប់ឱ្យធ្វើតេស្តបញ្ញាស្មារតីរបស់ជនជាប់ចោទប្រចាំត្រីមាស និងកាលវិភាគនៃការធ្វើតេស្ត
**Order for Quarterly Cognitive Testing of the Accused and Test Scheduling**

អង្គជំនុំជម្រះតុលាការកំពូល(“អង្គជំនុំជម្រះ”) រំលឹកការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងសម្បទារបស់ ខៀវ សំផន (“ជនជាប់ចោទ”) ក្នុងការចូលរួមជំនុំជម្រះ និងដីកាបង្គាប់ឱ្យធ្វើតេស្តផ្នែកបញ្ញាស្មារតីពេញមួយអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ (*សូមមើល*សេចក្តីសម្រេចចុងក្រោយលេខ E460/5 និងដីកាលេខ E460/6)។ ដោយហេតុថា កិច្ចដំណើរការនីតិវិធីក្នុងពេលបច្ចុប្បន្នស្ថិតក្នុងដំណាក់កាលបណ្តឹងសាទុក្ខ (*សូមមើល*ឯកសារលេខ E465 4/1) អង្គជំនុំជម្រះតុលាការកំពូលមានឆន្ទានុសិទ្ធិចេញដីកាបង្គាប់ឱ្យបន្តការធ្វើតេស្តជនជាប់ចោទផ្នែកបញ្ញាស្មារតីប្រចាំត្រីមាសតាមរយៈការធ្វើតេស្តផ្នែកបញ្ញាស្មារតី(“AMT”)ដោយអនុលោមតាមវិធាន ៣២ និង ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុង។

The Supreme Court Chamber (“The Chamber”) recalls the Trial Chamber’s issuance of Decisions concerning KHIEU Samphan’s (“the Accused”) fitness to stand trial and its Orders for cognitive testing throughout the Case 002 trial proceedings (*see latest* Decision E460/5

*and* Order E460/6). Given that the proceedings are now at the appellate stage (*see* E465 4/1), the Supreme Court Chamber uses its discretion to order the continuation of quarterly cognitive testing of the Accused through an Abbreviated Mental Test ("AMT") pursuant to Internal Rules 32 and 104 *bis*.

អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបួនរហូតមកដល់បច្ចុប្បន្នក្នុងការវាយតម្លៃសម្បទារបស់ ខៀវ សំផន ក្នុងការចូលរួមសវនាការនៅគ្រប់ពេល អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមប្រកបដោយអត្ថន័យក្នុងសំណុំរឿង ០០២ (E460/5, E389/6, E329/8, E301/12)។ ការវាយតម្លៃចុងក្រោយនៃសម្បទារបស់ជនជាប់ចោទបានប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨ (E460/3)។ សេចក្តីសម្រេចបានផ្អែកលើរបាយការណ៍របស់វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីនណា ("អ្នកជំនាញ") ដែលត្រូវបានជ្រើសតាំងដោយអនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង ក្នុងការវាយតម្លៃរបស់អ្នកជំនាញផ្នែកវិជ្ជសាស្ត្រ និងចិត្តសាស្ត្រលើជនជាប់ចោទ (E460)។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមជំនុំជម្រះ និងបានបង្គាប់ថា ផ្នែកបញ្ញាស្មារតីរបស់ជនជាប់ចោទត្រូវបន្តធ្វើតេស្តយ៉ាងហោចណាស់ម្តងរាល់ត្រីមាស ដោយត្រូវផ្តល់របាយការណ៍អំពីលទ្ធផលនេះទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

The Trial Chamber has issued four decisions to date assessing KHIEU Samphan's fitness to stand trial, each time finding the Accused capable of meaningful participation in Case 002 (E460/5, E389/6, E329/8, E301/12). The latest assessment of the Accused's fitness to stand trial was conducted on 29 January 2018 (E460/3). The decision was based on the reports of Dr. CHAN Kin Ming and Dr. HUOT Lina ("Experts"), who were appointed pursuant to Internal Rule 32 to conduct an expert medical and psychiatric evaluation of the Accused (E460). In its decision, the Trial Chamber found the Accused fit to stand trial and ordered that his cognitive function continue to be tested at least once every quarter, with the results to be reported to the Trial Chamber.

នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាកំណត់កាលបរិច្ឆេទបន្តការធ្វើតេស្តផ្នែកបញ្ញាស្មារតីប្រចាំត្រីមាសលើជនជាប់ចោទ តាមរយៈការធ្វើតេស្ត AMT សម្រាប់រយៈពេលចាប់ពី ខែ សីហា ឆ្នាំ ២០១៨ ដល់ ខែ ឧសភា ឆ្នាំ ២០១៩ (E460/6)។ ការធ្វើតេស្ត AMT ចុងក្រោយទាក់ទឹងជនជាប់ចោទ ប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៩ ដែលពេលនោះជនជាប់ចោទទទួលបានពិន្ទុ ៩/១០ (E13/441.1)។ បើពិន្ទុតិចជាង ឬស្មើនឹង ៦/១០ បង្ហាញថា មានភាពខ្សោយផ្នែកបញ្ញាស្មារតីក្នុងកម្រិតមួយ។

On 21 June 2018, the Trial Chamber issued an order scheduling the continuation of quarterly cognitive testing of the Accused through an AMT for the period from August 2018 to May

2019 (E460/6). The latest AMT performed in relation to the Accused took place on 29 May 2019 in which he scored 9/10 (E13/441.1). A score of less than or equal to 6/10 indicates a degree of cognitive impairment.

ដើម្បីធានាបាននូវការវាយតម្លៃផ្នែកបញ្ញាស្មារតីឱ្យបានទៀងទាត់លើជនជាប់ចោទរហូតដល់ពេលចេញសាលដីកាក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបង្គាប់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") សម្របសម្រួល និងដាក់កាលវិភាគធ្វើតេស្តរៀងរាល់ត្រីមាសដូចខាងក្រោម៖

- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៩
- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២០
- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០
- ចន្លោះពីថ្ងៃទី ១ ដល់ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០២០

In order to ensure the regular cognitive assessment of the Accused until delivery of the Appeal Judgement in Case 002/02, the Chamber directs WESU to coordinate and schedule the next quarterly tests during the following timeframes:

- Between 1 – 15 December 2019
- Between 1 – 15 March 2020
- Between 1 – 15 June 2020
- Between 1 – 15 September 2020

អង្គជំនុំជម្រះចាត់ទុកថា ជាការសមស្របដែលការបន្តធ្វើតេស្តនេះត្រូវប្រព្រឹត្តដោយមានការចូលរួមពីសាស្ត្រាចារ្យ ចក ធីតា និងវេជ្ជបណ្ឌិត ឈួរ ចាន់ណារា។ ស្របតាមយោបល់របស់វេជ្ជបណ្ឌិត CHAN Kin Ming អង្គជំនុំជម្រះបង្គាប់ថា ការធ្វើតេស្តត្រូវផ្លាស់ប្តូរជាប្រចាំដើម្បីជៀសវាងការទទួលបានលទ្ធផលដដែលៗ(ប្រតិចារិកចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ៣៥-៣៦)។ អង្គជំនុំជម្រះបង្គាប់បន្ថែមទៀតថា អង្គភាពពេទ្យត្រូវធានាថា ការធ្វើតេស្ត AMT ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមកាលវិភាគដែលបានកំណត់នៅក្នុងដីកានេះ និងប្រគល់លទ្ធផលអំពីការធ្វើតេស្ត AMT លើជនជាប់ចោទ ជូនមកអង្គជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននៅរៀងរាល់តេស្តនីមួយៗ។

The Chamber considers it appropriate that the continued cognitive testing be carried out jointly by Prof CHAK Thida and Dr CHHOUR Channara. In line with the advice of Dr CHAN Kin Ming, the Chamber orders that the tests be changed regularly to avoid results tainted with familiarity (T. 23 January 2015, pp 47- 48). The Chamber further orders the Medical Unit to ensure that the AMTs are administered in keeping with the schedule set out

in the present order and to submit to the Chamber the AMT results for the Accused as soon as possible after every respective test.